ដោយ អាឡេឡលី ក្លូវណែល-កាមីតាន់
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅប្រទេសហ្វីលីពីន ។*

ដេវ បានឮម្ដាយរបស់គាត់គោះទ្វារបន្ទប់គេងរបស់គាត់ ។ វាដល់ម៉ោងដែលត្រូវក្រោកពីដំណេក ។ គាត់រមៀលចុះពីគ្រែ ហើយលុបលាងមុខ ។ បន្ទាប់មកគាត់បានចូលរួមជាមួយម៉ាក់ប៉ា និងបងប្អូនរបស់គាត់នៅបន្ទប់ខាងមុខ ។

ម៉ាក់បាននិយាយថា « អរុណសួរស្ដី » ។ ដេវ ញញឹមទាំងងងុយគេង ។ ក្រុមគ្រួសារបានលុតជង្គង់ ហើយប៉ាបានអធិស្ឋានដើម្បីចាប់ផ្ដើមថ្ងៃរបស់ពួកគេ ។

ម៉ាក់បាននិយាយថា ៖ « ម៉ាក់ចង់ចែកចាយបទគម្ពីរដ៏អស្ចារ្យមួយនៅព្រឹកនេះ » ។ គាត់បានបើកព្រះគម្ពីរមរមន ។ « វានៅ ម៉ូរ៉ូណៃ ៧:៤៥ ។ ‹ សេចក្ដីសប្បុរស តែងតែអត់ធ្មត់ ហើយចិត្តល្អ › »

ដេវបានគិតអំពីបទគម្ពីរ ពេលគាត់ត្រៀមខ្លួនទៅសាលា ។ មុនពេលគាត់ដើរចេញពីទ្វារ គាត់បានអធិស្ឋាន ។ គាត់បានអធិស្ឋានថា ៖ « សូមជួយខ្ញុំឲ្យមានចិត្តសប្បុរសនៅថ្ងៃនេះ » ។

ក្នុងថ្នាក់ ដេវមានអារម្មណ៍សប្បាយចិត្តពេលគាត់ធ្វើកិច្ចការសាលា ។ គាត់បានស្ដាប់ដោយយកចិត្តទុកដាក់ ខណៈដែលអ្នកគ្រូ ហ្វ្រីដា បានឲ្យពាក្យអក្ខរាវិរុទ្ធថ្មីមួយចំនួនឲ្យពួកគេរៀន ។

មិនយូរប៉ុន្មានដល់ម៉ោងអាហារថ្ងៃត្រង់ ។ ដេវ បានទិញជំឡូងផ្អែម និងទឹកត្រជាក់ខ្លះៗ ។ គាត់អង្គុយជាមួយមិត្តភក្ដិរបស់គាត់ ហើយចាប់ផ្ដើមនិយាយគ្នា ។

មិនយូរប៉ុន្មានគាត់បានលឺក្មេងៗមួយចំនួននៅក្បែរនោះ ។ ក្មេងប្រុសពីរនាក់កំពុងញៀះញៀរក្មេងប្រុសថ្មីឈ្មោះ ហូសេ ។ ហូសេ តូចជាងអាយុរបស់គាត់ ប៉ុន្តែគាត់ជាមនុស្សល្អចំពោះអ្នកដទៃ ហើយបានខិតខំរៀន ។ ក្មេងប្រុសផ្សេងទៀតបានញ៉ាំអាហារថ្ងៃត្រង់ ប៉ុន្តែ ហូសេ មិនមានអ្វីញ៉ាំទេ ។

អាន់តូណីយ បានសួរថា « មិចបានជាឯងស្គមម្ល៉េះ ? តើឯងមិនមានអាហារនៅផ្ទះទេឬអី ? »

ដេវ បានងាកទៅក្មេងប្រុសៗទាន់ពេល បានឃើញ ដូខ្វីន យកកាបូបរបស់ ហូសេ ហើយបោះវាទៅឲ្យអាន់តូណីយ ។ ហូសេ បានរត់តាម អាន់តូណីយ ដើម្បីយកកាបូបរបស់គាត់មកវិញ ។

ហូសេ បាននិយាយថា « សូមឲ្យកាបូបមកខ្ញុំវិញ » ។

ប៉ុន្តែ អាន់តូណីយ និង ដូខ្វីន មិនស្ដាប់ ។ ដូខ្វីន បាននិយាយថា « កាបូបរបស់ឯងចាស់ហើយ ហើយមិនស្អាតទេ » ។

ដេវ បានឮពាក្យមិនល្អទាំងនេះ ប៉ុន្តែគាត់ខ្លាចដើម្បីទៅជួយ ហូសេ ។ តើក្មេងផ្សេងទៀតនឹងគិតបែបណាទៅ ? តើ ដូខ្វីន និង អាន់តូណីយ សើចចំអកនឹងគាត់ដែរទេ ?

បន្ទាប់មក គាត់បានគិតអំពីបទគម្ពីរដែលម៉ាក់បានអាននៅព្រឹកនោះ ។ *សេចក្ដីសប្បុរសគឺជាចិត្តល្អ* ។ ព្រះយេស៊ូវគ្រីស្ទចង់ឲ្យគាត់មានចិត្តសប្បុរស ។ វាជារឿងត្រឹមត្រូវដែលត្រូវធ្វើ ។

# ទង្វើល្អពេលអាហារថ្ងៃត្រង់

*តើក្មេងប្រុសផ្សេងទៀតសើចចំអកឲ្យគាត់ដែរឬទេ ?*





ដេវ ក្រោកឡើង ហើយតទល់នឹងក្មេងប្រុសផ្សេងទៀត ។ « ឈប់ធ្វើបាប ហូសេ ទៅ ។ សូមឲ្យកាបូបទៅគាត់វិញ » ។

ដូខ្វីន បានសួរថា « តើឯងមានបញ្ហាអ្វី ? »

ដេវ បាននិយាយថា « ហេតុអីក៏ពួកឯងធ្វើបាប ហូសេ ម្ល៉េះ ? គាត់មិនបានធ្វើអ្វីខុសនោះទេ » ។ បន្ទាប់មកគាត់បានដកដង្ហើមវែងៗ ។ « ព្រះយេស៊ូវស្រឡាញ់យើងទាំងអស់ ហើយទ្រង់ចង់ឲ្យយើងមានចិត្តសប្បុរស ។ សូមឈប់ធ្វើបាន ហូសេ ទៅ ។ ការធ្វើបាបគេគឺជារឿងខុស ។ បើពួកឯងនៅតែធ្វើទៀត ខ្ញុំនឹងប្រាប់អ្នកគ្រូ ហ្វ្រីដា ហើយ » ។

អាន់តូណីយ បានឈ្ងោកមើលស្បែកជើងគាត់ ។ គាត់បានឲ្យកាបូបទៅ ហូសេ វិញ ។ គាត់បានបន្ទាបខ្លួនដោយនិយាយថា « សូមទោស » ។ គាត់ និង ដូខ្វីន បានត្រឡប់ទៅកន្លែងអង្គុយរបស់ពួកគេ ។

ហូសេ បាននិយាយថា « អរគុណ » ។

ដេវ បានទះស្មារបស់ ហូសេ ។ « យើងជាមិត្តនឹងគ្នាតទ្បូវនេះ » ។

ហូសេ បានញញឹម ។

នៅផ្ទះ ដេវ បានប្រាប់គ្រួសាររបស់គាត់អំពីអ្វីដែលបានកើតឡើង ។

ប៉ាបាននិយាយថា ៖ « វាមិនងាយស្រួលទេ ប៉ុន្តែកូនបានធ្វើរឿងត្រឹមត្រូវហើយ » ។

ម៉ាក់បាននិយាយថា ៖ « ម៉ាក់មានមោទនភាពចំពោះកូនដែលមានចិត្តសប្បុរស ។

នៅថ្ងៃបន្ទាប់ពេលដែលម៉ាក់ជួយខ្ចប់អាហារថ្ងៃត្រង់របស់គាត់ ដេវ បានសួរថា « តើយើងអាចធ្វើនំសាំងវិចពីរបានទេ ?

ហេតុអ្វី ? តើកូនឃ្លានពេកមែនទេ ? » ម៉ាក់បានសួរ ។

ដេវ សើច ។ « ទេ ប៉ុន្តែកាលពីម្សិលមិញ ខ្ញុំបានសង្កេតឃើញថា ហូសេ មិនមានអីហូបទេ ។ កូនចង់ចែកចាយរបស់កូនខ្លះឲ្យទៅគាត់ » ។

« នោះជាគំនិតល្អណាស់ ! » ម៉ាក់បានយកនំប៉័ងមកបន្ថែម ហើយដេវធ្វើសាំងវិចមួយទៀត ។

នៅពេលអាហារថ្ងៃត្រង់ ដេវ និង ហូសេ បានអង្គុយញ៉ាំនំសាំងវិចជាមួយគ្នា ។ វាទាមទារឲ្យមានសេចក្ដីក្លាហានដើម្បីបញ្ឈប់ក្មេងដទៃទៀតឈប់ធ្វើបាបហូសេ ។ ប៉ុន្តែ ដេវ ស្រឡាញ់មិត្តថ្មីរបស់គាត់ ហើយគាត់បានដឹងថា ព្រះវរបិតាសួគ៌រីករាយដែលគាត់បានជ្រើសរើសធ្វើទង្វើល្អ ។ ●